# ព្រះរាជក្រឹត្យ

នស/រកត/០៧០១/២៤០

## ស្តីពីលក្ខន្តិកៈដោយឡែក
## នៃក្របខ័ណ្ឌគ្រូបង្រៀនកីឡាឧត្តម

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តមសីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

១ **ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ /នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- តាមសេចក្តីក្រាបបង្គំទូល ស្នើសុំ ពីនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០១ ។

Downloaded from http://www.khmerlaws.com

## ត្រាស់បង្គាប់

### ជំពូក ទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ត្រូវបានបង្កើតក្របខណ្ឌ គ្រូបង្រៀនកីឡាឧត្តមដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ ក ដូចមានចែងក្នុងមាត្រា៣ នៃព្រះរាជក្រឹត្យ នេន ជស-រកត ១២៩៧-២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំ មុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២ .-**

ក្របខ័ណ្ឌ គ្រូបង្រៀនកីឡាឧត្តមស្ថិតក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និង កីឡា ប្រមូលផ្តុំគ្រប់មន្ត្រីបច្ចេកទេស ខាងគរុកោសល្យ រឺង បច្ចេកទេសផ្សេងទៀត ដែលបានបណ្តុះបណ្តាល និងបំរើការនៅតាមគ្រឹះស្ថានសិក្សាសាធារណៈមធ្យមសិក្សាចំណេះទូទៅ មធ្យមសិក្សាបច្ចេកទេស ឧត្តមសិក្សា និងអង្គភាពជំនាញថ្នាក់កណ្តាល និងខេត្ត ក្រុង នៃក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៣ .-**

ក្របខ័ណ្ឌគ្រូបង្រៀនកីឡាឧត្តមមានមុខងារក្នុងតំណែងជាអ្នកបង្រៀន អ្នកសិក្សាស្រាវជ្រាវ និង មុខងារក្នុងតំណែងគ្រប់គ្រង ។

### ជំពូក ទី ២
### ឋានន្តរស័ក្តិ និង មុខតំណែង

**មាត្រា ៤ .-**

ក្របខ័ណ្ឌគ្រូបង្រៀនកីឡាឧត្តម មាន ៣ ឋានន្តរស័ក្តិ ÷

- ឋានន្តរស័ក្តិ ទី ១ ឬ ឋានន្តរស័ក្តិ គ្រូបង្រៀនកីឡាឧត្តម ជើងខ្សែពិសេស មាន ៦ ថ្នាក់
- ឋានន្តរស័ក្តិ ទី ២ ឬ ឋានន្តរស័ក្តិ គ្រូបង្រៀនកីឡាឧត្តម ជើងខ្សែ មាន ១០ ថ្នាក់
- ឋានន្តរស័ក្តិ ទី ៣ ឬ ឋានន្តរស័ក្តិ គ្រូបង្រៀនកីឡាឧត្តម មាន ១៤ ថ្នាក់ ។

**មាត្រា ៥ .-**

គ្រូបង្រៀនកីឡាឧត្តមមានឧបនិស្ស័យអាចកាន់មុខតំណែងគ្រប់គ្រងរួមជាមួយនឹងមន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅតាមគ្រឹះស្ថានសិក្សា និង អង្គភាពជំនាញនានា ដូចខាងក្រោម ÷

ឋានន្តរស័ក្តិទី ១ - សាកលវិទ្យាធិការ អគ្គនាយក អគ្គាធិការ

ឋានន្តរស័ក្តិទី ២ - សាកលវិទ្យាធិការរង ព្រឹទ្ធបុរសមហាវិទ្យាល័យ អគ្គនាយករង ល.ល.

Downloaded from http://www.khmerlaws.com

អគ្គាធិការរង អធិការ ប្រធាននាយកដ្ឋាន

ឋានន្តរស័ក្តិទី ៣
- ព្រឹទ្ធបុរសរង មហាវិទ្យាល័យ
- អនុប្រធាននាយកដ្ឋាន
- ប្រធានមន្ទីរ ខេត្ត ក្រុង
- អធិការរង
- នាយកមជ្ឈមណ្ឌល គរុកោសល្យ ភូមិភាគ
- នាយកសាលាគរុកោសល្យខេត្ត ក្រុង
- នាយកវិទ្យាល័យ

និង មុខតំណែងឯទៀតដែល មានថ្នាក់ស្មើនឹងមុខតំណែងខាងលើ នៃឋានន្តរស័ក្តិនីមួយៗនៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់ ក្រសួងអប់រំ យុវជន និង កីឡា ។

## ជំពូក ទី ៣
## ការជ្រើសរើស

**មាត្រា ៦ .-**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌគ្រូបង្រៀនកំរិតឧត្តម ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើសក្នុងចំណោមបេក្ខជន ជានិស្សិត ឬ និង ជាមន្ត្រីរាជការ របស់ក្រសួងអប់រំ យុវជន និង កីឡា និងមន្ត្រីរាជការផ្សេងទៀត ។

ចំនួនតំណែងក្នុងការជ្រើសរើសសំរាប់បេក្ខជនជានិស្សិត ឬនិងសំរាប់បេក្ខជនជាមន្ត្រីរាជការត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់ ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៧ .-**

ការប្រលងជ្រើសរើសក្នុងចំណោម និស្សិត ត្រូវបើកទូលាយ ចំពោះបេក្ខជនដែលមានអាយុ ច្រើនបំផុត ៣០ឆ្នាំ គិតមកដល់ថ្ងៃប្រលង ហើយមាន សញ្ញាប័ត្រទាបបំផុត បរិញ្ញាប័ត្រ ឬសញ្ញាប័ត្រសមមូល ។

លក្ខខណ្ឌ ក្នុងការប្រលងជ្រើសរើសចូលក្របខ័ណ្ឌ គ្រូបង្រៀនកំរិតឧត្តមសំរាប់បេក្ខជនជាមន្ត្រីរាជការត្រូវកំណត់ដោយក្រសួង អប់រំ យុវជន និង កីឡា ។

ការប្រលងជ្រើសរើសក្នុងចំណោមនិស្សិតត្រូវឆ្លងកាត់ការពិនិត្យសុខភាព និងកាយសម្បទា មុននឹងចូលសាលាបណ្តុះបណ្តាល ។ការពិនិត្យសុខភាព និងកាយសម្បទា លើកទី ២ ត្រូវអនុវត្តមុនធ្វើការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ។

លក្ខណៈវិនិច្ឆ័យកាយសម្បទា ត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និង កីឡា ។/.

Downloaded from http://www.khmerlaws.com

## ជំពូក ទី ៤
## ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៨ .-**

បេក្ខជនដែលបានជ្រើសរើសតាមរយៈការប្រលងជ្រើសរើស ក្នុងចំណោមនិស្សិត និង ក្នុងចំណោមមន្ត្រីរាជការ មានឋានៈ ជាគរុ និស្សិតកិត្តិឧត្តម ហើយត្រូវទទួលការបណ្តុះបណ្តាលដំបូង ដែលរៀបចំដោយក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៩ .-**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង គរុនិស្សិតកិត្តិឧត្តម ដែលប្រលងជាប់ត្រូវបានបែងចែកអោយទៅបំរើការងារនៅតាម ខេត្ត ក្រុង ឬ នៅថ្នាក់កណ្តាល ផ្អែកលើលទ្ធផលប្រលងបញ្ចប់ការបណ្តុះបណ្តាលហើយត្រូវបានតែងតាំងជាគ្រូបង្រៀនកិត្តិឧត្តមកម្មសិក្សា តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ។

គ្រូបង្រៀនកិត្តិឧត្តមកម្មសិក្សា ដែលបានជ្រើសរើសចេញពី និស្សិតត្រូវឆ្លងកាត់កម្មសិក្សាមួយដែលមានរយៈពេល ១២ខែ ។ ក្រោយពេលធ្វើកម្មសិក្សាសាកល្បង មន្ត្រីដែលត្រូវបានជ្រើសរើសចេញពីនិស្សិត ត្រូវបានតាំងស៊ប់ក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិ ទី ៣ ។

គ្រូបង្រៀនកិត្តិឧត្តម ដែលត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការ របស់ ក្រសួងអប់រំ យុវជន និង កីឡា ពុំចាំបាច់ឆ្លងកាត់ កម្មសិក្សាសាកល្បងឡើយ ។ ក្រោយពីបានទទួលការបណ្តុះបណ្តាលដំបូង មន្ត្រីទាំងនេះត្រូវបាន តាំងស៊ប់ ក្នុងឋានន្តរស័ក្តិទី ៣ ព្រមទាំងត្រូវបានទទួលសន្ទស្សន៍បៀវត្សខ្ពស់លើ បន្ទាប់ពីសន្ទស្សន៍ ចាស់របស់ខ្លួន ។

គ្រូបង្រៀនកិត្តិឧត្តមដែលត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការ ផ្សេងៗទៀត ត្រូវធ្វើ កម្មសិក្សាសាកល្បងរយៈ ពេល ៦ ខែ ដោយទទួលសន្ទស្សន៍ បៀវត្ស ខ្ពស់លើ បន្ទាប់ពីសន្ទស្សន៍ ចាស់ របស់ខ្លួន ។ ក្រោយពេលធ្វើកម្មសិក្សា សាកល្បង មន្ត្រី ទាំងនេះត្រូវបាន តាំងស៊ប់ ក្នុងឋានន្តរស័ក្តិទី ៣ និង ត្រូវទទួលបៀវត្ស តាមសន្ទស្សន៍ ដែលបានរៀបមកហើយ ។

គ្រូបង្រៀនកិត្តិឧត្តមកម្មសិក្សាដែល ធ្វើកម្មសិក្សាធ្លាក់ក្នុងពេលបំរើការត្រូវអនុញ្ញាតអោយបន្តកម្មសិក្សានៅឆ្នាំទី ២ ទៀត ។ ក្នុងករណី ធ្លាក់កម្មសិក្សានៅឆ្នាំ ទី ២ នេះ កម្មសិក្សាការីជ្រើសរើស ចេញមកពីនិស្សិតត្រូវលុបឈ្មោះចោល កម្មសិក្សាការី ជ្រើសរើសចេញ មកពីមន្ត្រីរាជការ ត្រូវ បញ្ជូនទៅ ក្របខ័ណ្ឌដើមវិញ ដោយគិតរយៈពេល ចូលសាលាបណ្តុះបណ្តាលសំរាប់អតីតភាពការងារ ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី ៣ នៃក្របខ័ណ្ឌគ្រូបង្រៀនកិត្តិឧត្តម ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។៚

Downloaded from http://www.khmerlaws.com

## ជំពូក ទី ៥
## ការតែងតាំង

**មាត្រា ១០ .-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌរួចហើយ គ្រូបង្រៀនកីឡាឧត្តមត្រូវបានតែងតាំងអោយបំពេញមុខងារក្នុងមុខតំណែងដូចមានចែងក្នុងមាត្រា ៣ ឬ អាចត្រូវបានតែងតាំង ក្នុងមុខតំណែងគ្រប់គ្រងទំនេរណាមួយ ដូចមានចែងក្នុងមាត្រា ៥ ខាងលើ ស្របតាមឋានន្តរស័ក្តិរបស់ខ្លួន តាមបែបបទដូចមានកំណត់ក្នុងមាត្រា ១៤ និង មាត្រាបន្តបន្ទាប់ នៃព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។

## ជំពូក ទី ៦
## ការដាក់អោយស្ថិតនៅក្រៅក្របខណ្ឌដើម

**មាត្រា ១១ .-**

គ្រូបង្រៀនកីឡាឧត្តមអាចត្រូវបានដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬ ក្រៅតំណែង ដើម្បីបំរើការនៅក្រសួងស្ថាប័នមួយផ្សេងទៀតតាមតំរូវការ និងតាមការយល់ព្រមពីសាមីជន ។

## ជំពូក ទី ៧
## ការតម្លើងថ្នាក់ និង ឋានន្តរស័ក្តិ

**មាត្រា ១២ .-**

គ្រូបង្រៀនកីឡាឧត្តម ត្រូវបានតម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយទៅតាមលក្ខខណ្ឌដូចបានចែងក្នុងមាត្រា ២០ និង មាត្រា បន្តបន្ទាប់ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

លក្ខណៈសម្បត្តិជាមូលដ្ឋាន ដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម ÷

-គំនិតផ្តួចផ្តើម ថ្នៃប្រឌិត និងលទ្ធផលការងារ

-មនសិការវិជ្ជាជីវៈ ស្មារតីទទួលខុសត្រូវ វិន័យការងារ

- ការយកចិត្តទុកដាក់ដល់ផលប្រយោជន៍ជាតិ

- សាមគ្គីភាព សីលធម៌រស់នៅ សកម្មភាពសង្គម ។

ការតម្លើងថ្នាក់ នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ ក្នុងវេនជ្រើសរើស និង ១ ភាគ ៤ តាមវេន អតីតភាព ។

ការតម្លើងថ្នាក់នៅក្នុងឋានន្តរស័ក្តិ គ្រូបង្រៀនកីឡាឧត្តម ដើមខ្សែពិសេស ត្រូវសំរេចដោយព្រះរាជក្រឹត្យ ។៨.

Downloaded from http://www.khmerlaws.com

ការតម្លើងថ្នាក់នៅក្នុងឋានន្តរស័ក្តិ គ្រូបង្រៀនកិត្តិឧត្តម ដើមខ្សែ ត្រូវសំរេចដោយអនុក្រឹត្យ ។

ការតម្លើងថ្នាក់នៅក្នុងឋានន្តរស័ក្តិ គ្រូបង្រៀនកិត្តិឧត្តម ត្រូវសំរេចដោយប្រកាស របស់ ក្រសួង អប់រំ យុវជន និង កីឡា។

**មាត្រា ១៣ .-**

គោលការណ៍ នៃការតម្លើងឋានន្តរស័ក្តិ តាមធម្មតាត្រូវតម្លើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬ ក្នុងករណី ចាំបាច់ត្រូវតម្លើងទៅក្នុងថ្នាក់ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ការតម្លើងឋានន្តរស័ក្តិ ត្រូវអនុវត្តតាមគោលការណ៍ ចំនួនមុខតំណែងគ្រប់គ្រងដែលមានទំនេរ ឬ គោលការណ៍ ភាគរយ ។ គោលការណ៍ភាគរយត្រូវបានកំណត់ ៧០% សំរាប់ឋានន្តរស័ក្តិទី ៣ ២៥% សំរាប់ឋានន្តរស័ក្តិទី ២ និង ៥% សំរាប់ឋានន្តរស័ក្តិ ទី ១។

ការតម្លើងឋានន្តរស័ក្តិនេះ ត្រូវធ្វើតាមរយៈការប្រឡងជ្រើសរើសដោយផ្អែកលើគុណវុឌ្ឍិនិងការវាយតំលៃ របស់ ឋានានុក្រម គ្រប់គ្រង ឬ តាមរយៈការបណ្តុះបណ្តាល និង ក្រឹត្យការជំនាញ រយៈពេលវែង នៅក្នុង ឬ ក្រៅប្រទេស ។

ការតម្លើងឋានន្តរស័ក្តិពីគ្រូបង្រៀនកិត្តិឧត្តមដើមខ្សែ ទៅ ឋានន្តរស័ក្តិ គ្រូបង្រៀនកិត្តិឧត្តមដើមខ្សែពិសេសត្រូវសំរេចដោយព្រះរាជក្រឹត្យ ។

ការតម្លើងពីឋានន្តរស័ក្តិគ្រូបង្រៀនកិត្តិឧត្តមទៅឋានន្តរស័ក្តិគ្រូបង្រៀនកិត្តិឧត្តមដើមខ្សែត្រូវសំរេចដោយអនុក្រឹត្យ ។

**មាត្រា ១៤ .-**

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិ គ្រូបង្រៀនកិត្តិឧត្តមដើមខ្សែ គឺ គ្រូបង្រៀនកិត្តិឧត្តមទាំងឡាយដែលបានឡើងដល់ថ្នាក់ លេខ ១១ ឡើងទៅ ក្នុងឋានន្តរស័ក្តិទី ៣ នៃក្របខ័ណ្ឌ គ្រូបង្រៀនកិត្តិឧត្តម។ អាចតម្លើងទៅក្នុងឋានន្តរស័ក្តិ គ្រូបង្រៀនកិត្តិឧត្តមដើមខ្សែ ពិសេស គឺ គ្រូបង្រៀនកិត្តិឧត្តមទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ ឡើងទៅ នៃឋានន្តរស័ក្តិ គ្រូបង្រៀនកិត្តិឧត្តម ដើមខ្សែ ។

**មាត្រា ១៥ .-**

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌគ្រូបង្រៀនកិត្តិឧត្តម និង តំលៃឯកតានៃសន្ទស្សន៍ ព្រមទាំងកិត្តិ លាភការ ផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។/.

Downloaded from http://www.khmerlaws.com

# ជំពូក ទី ៨
## ការតម្លើងថ្នាក់ និង ឋានន្តរស័ក្តិសំរាប់កាន់មុខតំណែង
## ជាអធិការមធ្យមសិក្សា

**មាត្រា ១៦ .-**

អធិការមធ្យមសិក្សា ជាមន្ត្រីបច្ចេកទេសអធិការកិច្ច ដែលបានបណ្តុះបណ្តាល សំរាប់មធ្យមសិក្សា ចំណេះទូទៅ បំរើការនៅថ្នាក់កណ្តាល និងខេត្ត ក្រុង ។

**មាត្រា ១៧ .-**

អធិការមធ្យមសិក្សាត្រូវបានជ្រើសរើសតាមការប្រលងជ្រើសរើស ក្នុងចំណោមមន្ត្រីរាជការជាគ្រូបង្រៀនកំរិតឧត្តមកំពុងបំរើការក្នុងក្រសួងអប់រំ យុវជន និង កីឡា ។

ចំនួនតំណែងក្នុងការជ្រើសរើសសំរាប់ការប្រលងនីមួយៗ ត្រូវកំណត់ឡើងដោយ ក្រសួងអប់រំ យុវជន និង កីឡា ។

លក្ខខណ្ឌនៃការប្រលងជ្រើសរើសមាន ៖

- ថ្នាក់លេខ ១១ ឡើងទៅ នៃ ឋានន្តរស័ក្តិគ្រូបង្រៀនកំរិតឧត្តម
- អាយុ យ៉ាងច្រើន ៤៥ ឆ្នាំ ។

**មាត្រា ១៨ .-**

បេក្ខជនដែលបានប្រលងជាប់ក្នុងការប្រលងជ្រើសរើស មានឋានៈ ជានិស្សិតអធិការមធ្យមសិក្សា ហើយត្រូវទទួលការបណ្តុះបណ្តាល ការងារអធិការកិច្ច ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និង កីឡា ។

បន្ទាប់ពីការបណ្តុះបណ្តាល និស្សិតអធិការមធ្យមសិក្សាដែលប្រលងជាប់ជាអធិការមធ្យមសិក្សាត្រូវបានតម្លើង ទៅក្នុងឋានន្តរស័ក្តិ ទី ២ ដោយអនុក្រឹត្យ ហើយត្រូវបានទទួល សន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់ខ្លួននិងត្រូវបានតម្លើងថ្នាក់ ១ ថ្នាក់ បន្ថែមជាស្វ័យប្រវត្តិ ។ អធិការមធ្យមសិក្សាត្រូវបានបែងចែកអោយទៅបំរើការនៅថ្នាក់កណ្តាល ឬ ខេត្ត ក្រុង តាមប្រកាសរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ១៩ .-**

អធិការមធ្យមសិក្សា ត្រូវទទួលប្រាក់រង្វាន់មុខតំណែងអធិការ ។

**មាត្រា ២០ .-**

ក្រៅពីគោលការណ៍ដែលមានកំណត់ក្នុងមាត្រា ១៧-១៨ និង ១៩ ខាងលើ អធិការមធ្យមសិក្សាត្រូវអនុវត្តគោលការណ៍ផ្សេងៗទៀត ដូចគ្រូបង្រៀនកំរិតឧត្តម ។ ន.វ.

Downloaded from http://www.khmerlaws.com

**មាត្រា ២១ .-**

ចំនួនដំបូង នៃអធិការមធ្យមសិក្សា ត្រូវកសាងចេញពីអធិការមធ្យមសិក្សាទាំងអស់ ដែលបច្ចុប្បន្ន កំពុងបំពេញមុខតំណែងពិតប្រាកដជាអធិការមធ្យមសិក្សា នៅក្នុងក្រសួងអប់រំ យុវជន និង កីឡា ។

## ជំពូក ទី ៩
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ២២ .-**

មន្ត្រីរាជការក្នុងក្របខ័ណ្ឌគ្រូបង្រៀនកិតិឧត្តម ត្រូវទទួលប្រាក់កំរៃគុណកោសល្យ ជាប្រាក់រង្វាន់ នៃមុខតំណែងគ្រូបង្រៀន ។

**មាត្រា ២៣ .-**

គ្រូបង្រៀនកិតិឧត្តម បំរើការរហូតដល់អាយុ ៦០ ឆ្នាំ ទើបចូលនិវត្តន៍ ។

ការដាក់អោយចូលនិវត្តន៍ នៅក្នុងឋានន្តរស័ក្តិ គ្រូបង្រៀនកិតិឧត្តមដើមខ្សែពិសេសត្រូវសំរេច ដោយព្រះរាជក្រឹត្យ ។

ការដាក់អោយចូលនិវត្តន៍ នៅក្នុងឋានន្តរស័ក្តិ គ្រូបង្រៀនកិតិឧត្តមដើមខ្សែ ត្រូវសំរេចដោយ អនុក្រឹត្យ ។

ការដាក់អោយចូលនិវត្តន៍ នៅក្នុងឋានន្តរស័ក្តិគ្រូបង្រៀនកិតិឧត្តមត្រូវសំរេចដោយប្រកាសរបស់ ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ២៤ .-**

គ្រូបង្រៀនកិតិឧត្តម ដែលក្រសួងចាត់អោយទៅទទួលការបំប៉ន ឬ ការបណ្តុះបណ្តាលបន្តរយៈ ពេលសរុបយ៉ាងតិច ១ឆ្នាំ នៅក្នុងជំនាញដែលបំរើអោយវិស័យអប់រំ យុវជន និង កីឡា ដោយមានវិញ្ញាបនប័ត្រ ឬ លិខិតបញ្ជាក់ការសិក្សាត្រូវបានទទួលការតម្លើងថ្នាក់ ១ ថ្នាក់ ជាស្វ័យប្រវត្តិតាមវេនជ្រើសរើស ។

ចំពោះគ្រូបង្រៀនកិតិឧត្តម ដែលត្រូវបានក្រសួងចាត់អោយទៅបន្តការសិក្សា ឬ បំប៉នជំនាញ ផ្សេងៗ រយៈពេលសិក្សានោះ ត្រូវបានគិតសំរាប់ការតម្លើងឋានន្តរស័ក្តិ ឬ ឡើងថ្នាក់ ។

**មាត្រា ២៥ .-**

ពេលចូលបំរើការដំបូង ឬក្នុងពេលបំរើការ គ្រូបង្រៀនកិតិឧត្តម ដែលមានសញ្ញាប័ត្រខ្ពស់ជាង បរិញ្ញាប័ត្រត្រូវបានតម្លើងថ្នាក់ជាស្វ័យប្រវត្តិ ១ ថ្នាក់ សំរាប់បរិញ្ញាប័ត្រជាន់ខ្ពស់ និង ២ថ្នាក់ សំរាប់សញ្ញាប័ត្រ ក្រោយបរិញ្ញាប័ត្រជាន់ខ្ពស់ ដោយមានការទទួលស្គាល់ ពីគណៈកម្មាធិការពិនិត្យ និងវាយតំលៃកិតិសញ្ញាប័ត្រ ស.ក.

Downloaded from http://www.khmerlaws.com

និង លិខិតបញ្ជាក់ការសិក្សា ។

**មាត្រា ២៦ .-**

សញ្ញាស័ក្តិ និងឯកសណ្ឋានសំរាប់គ្រូបង្រៀនកំរិតឧត្តមត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូក ទី ១០

## អន្តរប្បញ្ញត្តិ

**មាត្រា ២៧ .-**

ចំនួនដំបូង នៃក្របខ័ណ្ឌគ្រូបង្រៀនកំរិតឧត្តមត្រូវកសាងចេញពីសមាហរណកម្ម មន្ត្រីរាជការដែលបច្ចុប្បន្នកំពុងបំពេញ មុខតំណែង និង មុខងារពិតប្រាកដរបស់ក្របខ័ណ្ឌក្នុងគ្រឹះស្ថានសិក្សាគ្រប់កំរិត និងក្នុងអង្គភាពជំនាញ ថ្នាក់កណ្តាល និងតាម ខេត្ត ក្រុង របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ២៨ .-**

មុខតំណែងគ្រប់គ្រងនីមួយៗ ដែលត្រូវអនុវត្តតាមគោលការណ៍ក្របខ័ណ្ឌ ឋានន្តរស័ក្តិនិងថ្នាក់ខ្ពស់ជាងគេ មិនមានប្រតិកម្ម ទៅលើមុខតំណែងគ្រប់គ្រងបច្ចុប្បន្ន ដែលមានការតែងតាំងរួចហើយ លើកលែងតែមានការចាំបាច់ដែលជា សមត្ថកិច្ច របស់ ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ២៩ .-**

ក្នុងពេលប្រកាសបេក្ខជនបរិញ្ញាប័ត្រខាងភាសាបរទេស មានចំនួនមិនទាន់គ្រប់គ្រាន់ការប្រលងជ្រើសរើស គ្រូបង្រៀនកំរិតឧត្តម ផ្នែកភាសាបរទេសត្រូវធ្វើឡើងក្នុងចំណោមបេក្ខជនជាសិស្សមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិដែលមាន អាយុ ច្រើនបំផុត ២៥ ឆ្នាំហើយទទួលការបណ្តុះបណ្តាល យកបរិញ្ញាប័ត្រអប់រំដើម្បីតែងតាំងជា គ្រូបង្រៀនកំរិតឧត្តមកម្មសិក្សា ។

ក្រសួងអប់រំ យុវជន និង កីឡា ត្រូវស្នើសុំគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលមុននឹងធ្វើការប្រលងជ្រើសរើស ។

## ជំពូក ទី ១១

## អវសានប្បញ្ញត្តិ

**មាត្រា ៣០ .-**

បទប្បញ្ញត្តិណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។/.

Downloaded from http://www.khmerlaws.com

មាត្រា ៣១ .-

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣២ .-

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។ល។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

**ហ៊ុន សែន**

លេខៈ ១៥៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សោម គាន់**

Downloaded from http://www.khmerlaws.com